អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## អូស្ត្រាលីសន្យាផ្តល់ជំនួយថ្មីបន្ថែមចំនួន៣,២៥ លានដុល្លារអូស្ត្រាលីដល់អ.វ.ត.ក

រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី បានសន្យាផ្តល់ជំនួយថ្មីបន្ថែមទៀត ចំនួនទឹកប្រាក់ ៣,២៥ លានដុល្លារអូស្ត្រាលីដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី លោកព្រឹទ្ធសមាជិក ប៊ប់ ខា (Bob Carr) បានប្រកាសពីការសន្យាផ្តល់ជំនួយថវិកាថ្មីនេះ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០១៣ កន្លងទៅ។ លោករដ្ឋមន្ត្រី ប៊ប់ ខា មានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការថា៖ "សវនាការរបស់ អ.វ.ត.ក ដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការផ្តល់យុត្តិធម៌ជូនដល់ពលរដ្ឋខ្មែរដែលទទួលរងគ្រោះឈឺចាប់ខ្លោចផ្សាមិនអាចពិពណ៌នាបាននៅក្នុងអំឡុងរបបខ្មែរក្រហម"។

ជាមួយវិភាគទានថ្មីនេះ ប្រទេសអូស្ត្រាលី បានផ្តល់ជំនួយថវិកាដល់ អ.វ.ត.ក សរុបចំនួន ២៣ លាន ដុល្លារអូស្ត្រាលីហើយ រហូតមកទល់ពេលនេះ។ ដោយបានផ្តល់ជំនួយគាំទ្រតាំងពីតុលាការចាប់ផ្តើមដំណើរការមក ប្រទេសអូស្ត្រាលីគឺជាប្រទេសម្ចាស់ជំនួយអន្តរជាតិធំទី ២ សម្រាប់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោកខ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាល បានថ្លែងថា៖ "យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះការបន្តផ្តល់នូវការគាំទ្ររបស់រដ្ឋាភិបាលអូស្ត្រាលីនេះ។ វិភាគទាននេះ ត្រូវបានផ្តល់ ខណៈដែល អង្គជំនុំជម្រះសាលាដំបូង កំពុងស្ថិតនៅក្នុងដំណាក់កាល ឈានដល់ការបញ្ចប់សវនាការលើភស្តុតាង ក្នុងសំណុំរឿង ០០២/០១ និងដើម្បីធានាថាភាគីអន្តរជាតិនៃ អ.វ.ត.ក អាចមានលទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនដោយគ្មានភាពរអាក់រអួល"។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh